ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ....................សហវ.......

# របាយការណ៍

# និន្នាការសេដ្ឋកិច្ច-សង្គម

## ប្រចាំខែ កញ្ញា ឆ្នាំ ២០២៣

# Socio-Economic Trends Report

## September 2023

រៀបចំដោយ

នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច

អគ្គនាយកដ្ឋានគោលនយោបាយ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



Penh, Phnom Penh, CAMBODIA
mef.cabinet@mef.gov.kh

# មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប /Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា /Cambodia economic trends** | **៥** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ /Consumer price index | ៥ |
| ១.២. វិស័យពាណិជ្ជកម្ម /Trade | ៦ |
| ១.៣. វិស័យវិនិយោគឯកជន /Private investment | ៩ |
| ១.៤. វិស័យទេសចរណ៍ /Tourism | ១១ |
| ១.៥. វិស័យសំណង់ /Construction | ១១ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗ /Commodity prices** | **១៤** |
| ២.១. ថ្លៃប្រេង (Crude oil price: Brent, WTI, Dubai) | ១៤ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១៥ |
| **៣. ឧបសម្ព័ន្ធ** | **១៦** |

## **ខ្លឹមសារសង្ខេប** / Executive summary

*<u>តាមរយៈការតាមដានសូចនាករសេដ្ឋកិច្ច-សង្គមសំខាន់ៗ ក្នុងខែកញ្ញា ឆ្នាំ២០២៣ នេះ មាននិន្នាការដូចខាងក្រោម÷</u>*

**១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញក្នុងខែកញ្ញា ឆ្នាំ២០២៣ មានការកើនឡើង ៣,៨% ធៀបនឹងខែកញ្ញា ឆ្នាំ២០២២ (YoY)។** កំណើននេះចូលរួមចំណែកដោយ ការកើនឡើងនៃក្រុមសន្ទស្សន៍ថ្លៃសំខាន់ៗមួយចំនួនរួមមាន÷សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន កើនឡើង ៤,៨%, សន្ទស្សន៍ថ្លៃក្រុមអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង កើនឡើង ៤,៣%, សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ កើនឡើង ៤,០%, និងសន្ទស្សន៍ថ្លៃក្រុមដឹកជញ្ជូន កើនឡើង ២,៧%។

**២. ទំហំពាណិជ្ជកម្មសរុបក្នុងខែកញ្ញា ឆ្នាំ២០២៣ បានធ្លាក់ចុះវិញធៀបនឹងខែមុន ប៉ុន្តែនៅតែល្អជាងកាលពីខែកញ្ញា ឆ្នាំ២០២២។** ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ ទំហំពាណិជ្ជកម្មសរុបដកមាសសម្រេចបាន ៣៥ ១៦២ លានដុល្លារ បានធ្លាក់ចុះ ៣,៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២ ក្នុងនោះ ការនាំចេញថយចុះ ០,៨% និងការនាំចូលថយចុះ ២៥,២%។ ជារួម តុល្យភាពពាណិជ្ជកម្មក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ នេះ មានឱនភាពក្នុងទំហំប្រមាណត្រឹម ៦៧៥ លានដុល្លារ ដែលទាបជាងឱនភាពកាលពី ៩ខែ ដើមឆ្នាំ២០២២ ក្នុងទំហំ ៦ ៥០៦ លានដុល្លារ។

**៤. ការស្នើសាងសង់ក្នុងខែកញ្ញា ឆ្នាំ២០២៣ បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ធៀបនឹងខែមុន ទាំងចំនួនគម្រោងនិងផ្ទៃក្រឡាសំណង់។** ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ ចំនួនគម្រោង មានចំនួន ២ ៥៩៨ គម្រោងថយចុះ ១៩% ខណៈដែលផ្ទៃក្រឡាសាងសង់ មាន ១១,៩៩ លានម៉ែត្រការ៉េ កើនឡើង ១៤៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២។

**៥. ចំនួនគម្រោងវិនិយោគដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែកញ្ញា ឆ្នាំ២០២៣ ថយចុះបន្តិច ខណៈដែលទុនវិនិយោគ បានបន្តកើនឡើង។** ក្នុងខែកញ្ញា ឆ្នាំ២០២៣ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តគម្រោងវិនិយោគ ២៧ គម្រោង (ថយចុះ ៩ គម្រោង ធៀបនឹងខែមុន) ដែលក្នុងនោះ គម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១៨ គម្រោង (១៧ ជាគម្រោងថ្មី និង ១ ជាគម្រោងពង្រីកចង្វាក់ផលិតកម្ម) និងក្រៅតំបន់សេដ្ឋកិច្ចពិសេសមានគម្រោងថ្មីចំនួន ៩ គម្រោង។ ការវិនិយោគនេះ ប្រើប្រាស់ទុនសរុប ប្រមាណ ១ ៦២៤ លានដុល្លារ កើនឡើង ៨៣% ធៀបនឹងខែមុន។ ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ គម្រោងវិនិយោគសរុបមានចំនួន ១៩១ គម្រោង ដែលបានប្រើប្រាស់ទុនសរុបប្រមាណ ៣ ៧៦៥ លានដុល្លារ។

**៦. ទោះបីជាមានការឡើងថ្លៃក្នុងរយៈពេល ៣ខែចុងក្រោយនេះ, ថ្លៃប្រេងឥន្ធនៈក្នុងស្រុក និងថ្លៃមធ្យមប្រេងឆៅអន្តរជាតិ ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៣ នៅតែស្ថិតក្នុងសភាពល្អប្រសើរជាងថ្លៃជាមធ្យមឆ្នាំ២០២២។** ក្នុងខែកញ្ញា ឆ្នាំ២០២៣ ថ្លៃមធ្យមប្រេងឥន្ធនៈ (ប្រេងសាំងធម្មតា និងប្រេងម៉ាស៊ូត) លក់រាយនៅកម្ពុជា ស្ថិតក្នុងរង្វង់ ៤ ៧១៧ រៀល/លីត្រ កើនឡើង ១១៧ រៀល/លីត្រ ឬ ២,៥% ធៀបនឹងខែមុន ក្នុងនោះ ថ្លៃប្រេងសាំង កើនឡើង ១,៥% និងថ្លៃប្រេងម៉ាស៊ូត កើនឡើង ៣,៦%, ខណៈដែលថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិកើនឡើង ៨,៩%។ យ៉ាងណាមិញ ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ ថ្លៃមធ្យមប្រេងឥន្ធនៈលក់រាយនៅកម្ពុជា ថយចុះ ១៤,៨% ស្របពេលដែលប្រេងឆៅនៅលើទីផ្សារអន្តរជាតិ ថយចុះប្រមាណ ២០,៥%។

**សន្និដ្ឋាននិន្នាការសូចនាករសំខាន់ៗ ក្នុងខែកញ្ញា ឆ្នាំ២០២៣ និងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣÷** សកម្មភាពសេដ្ឋកិច្ច ក្នុងខែកញ្ញានេះ ហាក់មានសភាពស្ងប់ស្ងាត់បន្តិច និងក៏ទទួលរងឥទ្ធិពលនៃកំណើនអតិផរណា ដែលជាលទ្ធផលក្នុងសូចនាករសេដ្ឋកិច្ចបានបង្ហាញថា ថ្លៃទំនិញនិងថ្លៃម្ហូបអាហារបានបន្តកើនក្នុងកម្រិតស្ទួចស្ទើង, សកម្មភាពពាណិជ្ជកម្មមានទំហំតូចជាងខែមុន, ការមកដល់នៃទេសចរបានធ្លាក់ចុះវិញបន្តិច, សកម្មភាពសាងសង់ពុំទាន់ចាប់ផ្តើមអភិវឌ្ឍន៍លើគម្រោងថ្មី និងការវិនិយោគបានថយចុះជាងខែមុន។ ដោយឡែក ជាលទ្ធផលក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ បានបង្ហាញថា សន្ទស្សន៍ថ្លៃទំនិញ និងសេវាកម្ម បានកើនឡើងក្នុងកម្រិតមធ្យម ខណៈដែលថ្លៃប្រេងសាំងទាំងក្នុងស្រុកនិងអន្តរជាតិ កើនឡើងក្នុងកម្រិតទាប, អានុភាពនៃការនាំចេញបានបង្ហាញឱនភាពនៃជញ្ជីងពាណិជ្ជកម្ម, ទេសចរសម្រេចបានកំណើនខ្ពស់, សកម្មភាពសាងសង់កំពុងមានដំណើរការល្អប្រសើរឡើងវិញ, និងលក្ខខណ្ឌវិនិយោគដ៏ទាក់ទាញបានជំរុញកំណើនវិនិយោគគួរឱ្យកត់សម្គាល់ (តារាង ១÷ ស្ថិតិសង្ខេបសេដ្ឋកិច្ចតាមវិស័យ ប្រចាំខែកញ្ញា ឆ្នាំ២០២៣)។ ការរំពឹងកំណើនសម្រាប់ខែបន្ទាប់រហូតដល់ចុងឆ្នាំនេះ នឹងផ្តល់នូវសុទិដ្ឋិនិយមខ្ពស់ ដោយផ្អែកលើ ការមកដល់នូវកម្មវិធីប្រពៃណីជាច្រើន, ការបើកឱ្យដំណើរការនូវបណ្តាហេដ្ឋារចនាសម្ព័ន្ធមួយចំនួន រួមមាន ស្ពានកោះនរា និងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ជាដើម, ការអនុម័តគម្រោងផ្លូវល្បឿនលឿន និងការខិតចូលមកដល់នៃរដូវរងាខ្ពស់ … 

| តារាង១÷ ស្ថិតិសង្ខេបសេដ្ឋកិច្ចតាមវិស័យ ប្រចាំខែកញ្ញា ឆ្នាំ២០២៣ | | | | កើន/ថយ | | |
|---|---|---|---|---|---|---|
| | | ឯកតា | តម្លៃ | ខែមុន | កញ្ញាឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| **I** | **សន្ទស្សន៍ថ្លៃ និងថ្លៃទំនិញ** | | | | | |
| | -សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញ | សន្ទស្សន៍ | 204.80 | 0.02% | 3.75% | 1.81% |
| | -សន្ទស្សន៍ថ្លៃម្ហូបអាហារ | សន្ទស្សន៍ | 258.80 | 0.21% | 4.38% | 3.09% |
| | -ថ្លៃប្រេងសាំង | រៀល/លីត្រ | 4,650 | 1.45% | 3.72% | -12.83% |
| | -ថ្លៃប្រេងម៉ាស៊ូត | រៀល/លីត្រ | 4,783 | 3.61% | -7.72% | -16.64% |
| | -ថ្លៃអង្ករផ្កាម្លិះ | រៀល/គ.ក | 4,009 | -0.90% | 10.34% | 5.29% |
| | -ថ្លៃអង្ករផ្កាខ្ញី | រៀល/គ.ក | 3,317 | 1.51% | 24.52% | 13.03% |
| | -ថ្លៃអង្ករនាងមិញ | រៀល/គ.ក | 3,136 | 6.6% | 11.64% | 2.63% |
| | -ថ្លៃសាច់ត្រី | រៀល/គ.ក | 12,351 | 10.95% | 7.12% | -1.49% |
| | -ថ្លៃសាច់ជ្រូក | រៀល/គ.ក | 21,194 | -8.35% | -4.62% | -1.24% |
| | -ថ្លៃប្រេងឆៅ (Brent) | USD/BBL | 94.00 | 9.10% | 4.26% | -20.74% |
| | -ថ្លៃប្រេងឆៅ (WTI) | USD/BBL | 89.58 | 10.05% | 6.81% | -21.21% |
| | -ថ្លៃអង្ករថៃ (ប្រភេទអង្ករបាក់ ៥%) | USD/MT | 620.00 | -2.36% | 41.23% | 23.29% |
| | -ថ្លៃអង្ករវៀតណាម (ប្រភេទអង្ករបាក់ ៥%) | USD/MT | 594.37 | 9.83% | 51.53% | 22.66% |
| **II** | **ពាណិជ្ជកម្មជា** | | | | | |
| | ***ការនាំចេញទំនិញសរុប (ដកមាស)*** | **លានដុល្លារ** | ***1,881.01*** | ***-11.21%*** | ***17.23%*** | ***-0.77%*** |
| | -ផលិតផលវាយនភណ្ឌ | លានដុល្លារ | 953.92 | -5.26% | -3.25% | -17.60% |
| | -ផលិតផលមិនមែនវាយនភណ្ឌ | លានដុល្លារ | 927.09 | -16.59% | 49.88% | 23.65% |
| | -ក្នុងនោះ ផលិតផលកសិកម្ម* | លានដុល្លារ | 187.92 | -37.19% | 42.78% | 17.88% |
| | ***ការនាំចូលសរុប (ដកមាស)*** | **លានដុល្លារ** | ***1,955.08*** | ***-6.57%*** | ***4.06%*** | ***-5.92%*** |
| | -ប្រេងឥន្ធនៈ | លានដុល្លារ | 214.19 | 3.57% | -15.09% | -12.85% |
| | -វត្ថុធាតុដើមកាត់ដេរ | លានដុល្លារ | 409.38 | 6.67% | 29.55% | -13.15% |
| | -គ្រឿងសំណង់ | លានដុល្លារ | 162.65 | -8.91% | 43.15% | 0.76% |
| | -វត្ថុធាតុដើមកសិកម្ម (ជីកសិកម្ម) | លានដុល្លារ | 33.23 | 6.11% | 50.75% | 18.20% |
| | -គ្រឿងហូបចុក (Food stuff) | លានដុល្លារ | 58.01 | 0.35% | 34.18% | 9.75% |
| **III** | **ទេសចរ** | | | | | |
| | -ភ្ញៀវទេសចរអន្តរជាតិ | នាក់ | 424,901 | -8.55% | 58.84% | 296.51% |
| | -ភ្ញៀវទេសចរក្នុងស្រុក | នាក់ | 648,902 | 20.38% | -21.82% | 32.33% |
| | -ភ្ញៀវទេសចរអន្តរជាតិទិញសំបុត្រពីគ្រឹះស្ថានអង្គរ | នាក់ | 41,048 | -30.60% | 74.06% | 302.2% |
| **IV** | **សាងសង់** | | | | | |
| | -ចំនួនគម្រោងដែលទទួលបានការអនុញ្ញាតសាងសង់ | គម្រោង | 231 | -30.21% | -36.54% | -18.17% |
| | -ទំហំទឹកប្រាក់សាងសង់ | លានដុល្លារ | 202 | -87.01% | -45.86% | 153.16% |
| | -ផ្ទៃក្រឡាសាងសង់ | ម៉ែត្រការ៉េ | 427,582 | -88.00% | -31.87% | 146.36% |
| **V** | **គម្រោងវិនិយោគ** | | | | | |
| | -គម្រោងវិនិយោគឯកជន | គម្រោង | 27 | -25.00% | 107.7% | 41.48% |
| | -កម្លាំងពលកម្មថ្មី | នាក់ | 32,048 | -37.69% | 67.34% | 104.10% |
| | -ទុនវិនិយោគសរុប | លានដុល្លារ | 1,624 | 82.94% | 784.61% | 8.84% |
| **VI** | **ហិរញ្ញវត្ថុសាធារណៈ** | | | | | |
| | -ចំណូលក្នុងស្រុកសរុបថ្នាក់ជាតិ | ពាន់លានរៀល | 1,613.41 | -14.44% | -16.00% | -1.26% |
| | -ចំណាយសរុបថ្នាក់ជាតិ | ពាន់លានរៀល | 1,389.71 | -4.76% | 9.29% | -0.73% |
| **VII** | **វិស័យរូបិយវត្ថុ** | | | | | |
| | -ឥណទានវិស័យឯកជន | ពាន់លានរៀល | | | | |
| | -ទុនបម្រុងជារូបិយប័ណ្ណបរទេសដុល (លានដុល្លារអាមេរិក) | លានដុល្លារ | 18,070 | -2.63% | 2.30% | -5.91% |
| | -អត្រាប្តូរប្រាក់ផ្លូវការនាចុងខែ (រៀល/ដុល្លារ) | រៀល | 4,122.00 | -0.87% | 0.07% | 0.78% |

*សម្គាល់* ផលិតផលកសិកម្ម រួមមាន÷ ស្រូវ, ដំឡូងមី, ពោត, សណ្តែក, ចេក, ស្វាយ, ស្វាយចន្ទី, ផលិតផលជលផល និងផលិតផលកសិកម្មដ៏ទៃទៀត

សំណង់ រួមមាន÷ គ្រឿងបរិក្ខារសំណង់, ស៊ីម៉ង់ និងដែកថែប។

# ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

## ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

តាមរយៈទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិក្នុងខែកញ្ញា ឆ្នាំ២០២៣, សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម នៅរាជធានីភ្នំពេញ កើនឡើង ០,០២% ធៀបនឹងខែមុន និង ៣,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដែលកំណើននេះ គឺដោយសារ សន្ទស្សន៍ថ្លៃម្ហូបអាហារ(ឆ្នាំធៀបឆ្នាំ) កើនឡើង ៤,៤% ក្នុងនោះ÷(១). សន្ទស្សន៍ថ្លៃត្រីទឹកសាប និងត្រីសមុទ្រ កើនឡើង ៥,៦%, (២). សន្ទស្សន៍ថ្លៃអង្ករ កើនឡើង ២,០%, និង(៣). សន្ទស្សន៍ថ្លៃសាច់ កើនឡើង ២,០% (សាច់ជ្រូក កើនឡើង ២,២%, សាច់ទាស្រស់ កើនឡើង ២,២%, សាច់មាន់ស្រស់ កើនឡើង ២,១%, និងសាច់គោស្រស់ កើនឡើង ១,៨%)។ ទន្ទឹមនេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មផ្សេងទៀត ដែលមានអត្រាកំណើនគួរឱ្យកត់សម្គាល់ រួមមាន÷ (១). សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន កើនឡើង ៤,៨%, (២). សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ កើនឡើង ៤,០%, និង (៣). សន្ទស្សន៍ថ្លៃក្រុមដឹកជញ្ជូន កើនឡើង ២,៧%។ ក្នុងខែកញ្ញា ឆ្នាំ២០២៣, សន្ទស្សន៍ថ្លៃក្រុមដឹកជញ្ជូន បានកើនឡើងវិញបន្តិច, ខណៈដែលថ្លៃប្រេងឥន្ធនៈស្ថិតនៅក្នុងស្ថានភាពល្អប្រសើរនៅឡើយ ពោលគឺស្ថិតក្នុងអត្រា-២,៤% ធៀបនឹងខែកញ្ញា ឆ្នាំ២០២២ ក្នុងនោះ ថ្លៃប្រេងសាំង ៤ ៦៥០ រៀល/លីត្រ (កើនឡើង ៣,៧%) និង ថ្លៃប្រេងម៉ាស៊ូត ៤ ៧៨៣ រៀល/លីត្រ (ថយចុះ ៧,៧%)។

ក្រាហ្វិច ១÷ សន្ទស្សន៍ថ្លៃម្ហូបអាហារឆ្នាំធៀបឆ្នាំ (Y-o-Y)




*ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ*




*ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងពាណិជ្ជកម្ម*

## ១.២. វិស័យពាណិជ្ជកម្ម / Trade

**ក. ការនាំចេញដកមាស÷** ក្នុងខែកញ្ញា ឆ្នាំ២០២៣, ការនាំចេញទំនិញរបស់កម្ពុជា សម្រេចបានក្នុងទំហំទឹកប្រាក់ចំនួន ១ ៨៨១ លានដុល្លារ (ស្មើនឹង ៥,៨% នៃ ផ.ស.ស.) បានធ្លាក់ចុះ ១១,២% ធៀបនឹងខែមុន ដែលជាលទ្ធផលនៃការថយចុះការនាំចេញផលិតផលសំខាន់ៗមួយចំនួនរួមមាន ផលិតផលវាយនភណ្ឌ ធ្លាក់ចុះ ៥,៣%, គ្រឿងបង្គុំអគ្គិសនី ធ្លាក់ចុះ ១៨,៦%, កង់ ធ្លាក់ចុះ ៣៥%, ដំឡូងមី ធ្លាក់ចុះ ៩%, ស្វាយចន្ទី ធ្លាក់ចុះ ៤៧,៤%, ជលផល ៧,៦%, កសិផលផ្សេងៗ ធ្លាក់ចុះ ៩៧,១%, កំប៉ុងដែក និងអាលុយមីញ៉ូម ធ្លាក់ចុះ ៩៤,៤%, និងផលិតផលនាំចេញផ្សេងទៀត ធ្លាក់ចុះ ៨,៥% ធៀបនឹងខែមុន។ គួរកត់សម្គាល់ផងដែរ ក្នុងបណ្តាផលិតផលនាំចេញមួយចំនួនទៀតក្នុងខែនេះ បាននិងកំពុងកើនឡើងវិញ ក្នុងនោះ គ្រឿងបន្លាស់យានយន្ត កើនឡើង ១,៤%, អង្ករ កើនឡើង ៩៩,៤%, ពោត មានកំណើនក្នុងទំហំប្រមាណជាង ៣ លានដុល្លារ (ខែមុន ពុំមានការនាំចេញ), សណ្តែក កើនឡើង ៣៣,៩%, ចេក កើនឡើង ១៩,៩%, ស្វាយ កើនឡើង ១២៤,៣%, ជ័រកៅស៊ូ កើនឡើង ៤៦,២%, ស្ករស កើនឡើង ១៦១,៥%, ខ្សែចម្លង និងកាបអ៊ុបទិក កើនឡើង ៧%, និងសូឡា កើនឡើង ៥,២%។ ដោយឡែក បើធៀបនឹងខែកញ្ញា ឆ្នាំ២០២២ ទំហំទឹកប្រាក់នាំចេញក្នុងខែកញ្ញា នេះ បានកើនឡើង ១៧,២%។

បើគិតត្រឹមរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ ការនាំចេញទំនិញរបស់កម្ពុជាសម្រេចបានក្នុងទំហំទឹកប្រាក់ប្រមាណជាង ១៦ ៩៤៦ លានដុល្លារ (ស្មើនឹង ៥២,៧% នៃ ផ.ស.ស.) ធ្លាក់ចុះតិចតួចក្នុងរង្វង់ ០,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដោយសារមុខទំនិញនាំចេញសំខាន់ៗនៅតែទទួលរងសម្ពាធពីការធ្លាក់ចុះតម្រូវការជាសកល ដែលមានដូចជា ផលិតផលវាយនភណ្ឌ ធ្លាក់ចុះ ១៧,៦%, កង់ ធ្លាក់ចុះ ៤៨,៦%, និងខ្សែចម្លង និងកាបអ៊ុបទិក ធ្លាក់ចុះ ២១,៧%

ជាដើម។ យ៉ាងណាមិញ, ផលិតផលនាំចេញមួយចំនួនទៀត ក៏មានកំណើនល្អគួរឱ្យកត់សម្គាល់ផងដែរ ក្នុងនោះរួមមាន គ្រឿងបន្លាស់យានយន្ត អង្ករ ដំឡូងមី ស្វាយចន្ទី ជ័រកៅស៊ូ ស្ករស និងកសិផលផ្សេងទៀត កើនឡើង ៤០,៩%, ១២,៦%, ០,៨%, ៤៩,៦%, ៥,១%, ៤៦,៦%, និង ៤៧,៧% រៀងគ្នាធៀបនឹង ៩ខែ ឆ្នាំមុន។



ក្រាហ្វិច ៣÷ ទឹកប្រាក់នាំចេញ (គិតជាលានដុល្លារ) ធ្លាក់ចុះធៀបនឹងខែមុន ប៉ុន្តែកើនឡើងធៀបនឹងឆ្នាំមុន (ដកមាស)

*ប្រភព÷ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

ក្នុងខែកញ្ញា ឆ្នាំ២០២៣ ការនាំចេញទំនិញរបស់កម្ពុជាទៅកាន់ទីផ្សារ អាស៊ាន អឺរ៉ុប សហរដ្ឋអាមេរិក ចិន និង អង់គ្លេស បានធ្លាក់ចុះ ខណៈដែលការនាំចេញទៅ ជប៉ុន និងប្រទេសដទៃទៀតមានការកើនឡើងវិញធៀបនឹងខែមុន។ បើគិតត្រឹម ៩ខែ ដើមឆ្នាំ២០២៣ នេះ ការនាំចេញទៅទីផ្សារអាស៊ាន និងចិន មានកំណើនល្អគួរឱ្យកត់សម្គាល់ ពោលគឺ អាស៊ានក្នុងរង្វង់ ៣៨,៤% និងប្រទេសចិនក្នុងរង្វង់ ១៨,៣% ខណៈដែល អឺរ៉ុប សហរដ្ឋអាមេរិក ជប៉ុន អង់គ្លេស និង ប្រទេសផ្សេងៗ បានធ្លាក់ចុះក្នុងរង្វង់ ១០,៥%, ២,១%, ១,៣%, ១៣,៦%, និង៨,២% រៀងគ្នាធៀបនឹងរយៈពេល ៩ខែ ដើមឆ្នាំ២០២២។

*ក្រាហ្វិច ៤÷ ទីផ្សារអាម៉េរិក, អឺរ៉ុប និង អាស៊ានបានរួមចំណែកធំក្នុងទីផ្សារនាំចេញរបស់កម្ពុជាក្នុងខែកញ្ញា*




*ប្រភព÷ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

*តារាង ២. ទំហំទឹកប្រាក់នាំចេញតាមមុខទំនិញសំខាន់ៗក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣*

| **ទំនិញ (គិតជាលានដុល្លារ)** | **ទំហំទឹកប្រាក់នាំចេញ** | **សមាមាត្រជាភាគរយ** |
|---|---|---|
| វាយនភណ្ឌ | 8,332 | 47.4% |
| កង់ | 360 | 2.0% |
| អង្ករ | 328 | 1.9% |
| ដំឡូងមី | 539 | 3.1% |
| ជ័រកៅស៊ូ | 287 | 1.6% |
| ទំនិញផ្សេងៗ | 7,100 | 40.3% |
| សរុបដកមាស | 16,946 | 96.3% |

ទំនិញនាំចេញដកមាសមាន ៩៦,៣% នៃទំនិញនាំចេញសរុប

*ប្រភព÷ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

**ខ. ការនាំចូលដកមាស÷** ការនាំចូលទំនិញរបស់កម្ពុជាក្នុងខែកញ្ញា ឆ្នាំ២០២៣ សម្រេចបានក្នុងទំហំទឹកប្រាក់ចំនួន ១ ៩៥៥ លានដុល្លារ (ស្មើនឹង ៦,១% នៃ ផ.ស.ស.) បានធ្លាក់ចុះ ៦,៦% ធៀបនឹងខែមុន ដោយសារការថយចុះក្នុងការនាំចូលផលិតផលសំខាន់ៗមួយចំនួន រួមមាន គ្រឿងសំណង់ ធ្លាក់ចុះ ៨,៩%, យានយន្ត ធ្លាក់ចុះ ១,១%, ថ្នាំពេទ្យ ធ្លាក់ចុះ, សម្លៀកបំពាក់ថ្មី ៥,៨% និងផលិតផលនាំចូលផ្សេងទៀត ធ្លាក់ចុះ ១២,៤%។ គួរកត់សម្គាល់ផងដែរ ក្នុងខែកញ្ញានេះ ការនាំចូលក្រណាត់ កើនឡើង ៦,៧%, ប្រេងឥន្ធនៈ កើនឡើង ៣,៦%, ជីកសិកម្ម កើនឡើង ៦,១%, ទូរស័ព្ទដៃ កើនឡើង ២ ១០៥%, និងគ្រឿងបន្លាស់យានយន្ត កើនឡើង ១៧,៣% ធៀបនឹងកាលពីខែសីហាកន្លងទៅ។ ដោយឡែក បើធៀបនឹងខែកញ្ញា ឆ្នាំ២០២២ ទំហំទឹកប្រាក់នាំចូលក្នុងខែកញ្ញានេះ បានធ្លាក់ចុះ ១៥,៧%។

ទន្ទឹមនេះ, ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ ការនាំចូលទំនិញរបស់កម្ពុជា សម្រេចបានក្នុងទំហំទឹកប្រាក់ចំនួន ១៨ ២១៧ លានដុល្លារ (ស្មើនឹង ៥៦,៦% នៃ ផ.ស.ស.) ធ្លាក់ចុះប្រមាណ ៥,៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០២២ ដោយសារការថយចុះនៃការនាំចូលក្រណាត់ ១៣,២%, យានយន្ត ៣៤,៤%, ប្រេងឥន្ធនៈ ១២,៨%, ថ្នាំពេទ្យ ៨,៩%។ គួរឱ្យកត់សម្គាល់ផងដែរ ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ នេះ ផលិតផលនាំចូលមួយចំនួនក៏សម្រេចបានកំណើនល្អផងដែរ ដែលមានដូចជា គ្រឿងសំណង់ កើនឡើង ៣%, ជីកសិកម្ម ១៨,២%, គ្រឿងបន្លាស់យានយន្ត កើនឡើង ១០៦,៤%, ឧបករណ៍អេឡិចត្រូនិក កើនឡើង ១៥,៣% និងទំនិញនាំចូលផ្សេងៗ កើនឡើង ០,២% ជាដើម។

ក្រាហ្វិច ៥÷ ទឹកប្រាក់នាំចូល (គិតជាលានដុល្លារ) ធ្លាក់ចុះធៀបនឹងខែមុន ប៉ុន្តែកើនឡើងធៀបនឹងឆ្នាំមុន (ដកមាស)




*ប្រភព÷ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

ក្នុងខែកញ្ញា ឆ្នាំ២០២៣ ការនាំចូលទំនិញរបស់កម្ពុជាមកពីទីផ្សារ អាស៊ាន សហរដ្ឋអាមេរិក ជប៉ុន អង់គ្លេស និងប្រទេសដទៃទៀតបានធ្លាក់ចុះ ខណៈដែលការនាំចូលមកពីទីផ្សារអឺរ៉ុប និងចិន បានកើនឡើងវិញ។ បើគិតត្រឹម ៩ខែដើមឆ្នាំ២០២៣ នេះ ការនាំចូលមកពីទីផ្សារអឺរ៉ុប ចិន ជប៉ុន និងអង់គ្លេស សម្រេចបានកំណើនល្អគួរឱ្យកត់សម្គាល់ពោលគឺ អឺរ៉ុបកើនឡើងក្នុងរង្វង់ ៤៣,៣%, ចិន កើនឡើង ០,៨%, ជប៉ុន កើនឡើង ២,៣%, និងអង់គ្លេស កើនឡើង ៧% ខណៈដែលទីផ្សារនាំចូលមកពីអាស៊ាន និងសហរដ្ឋអាមេរិក និងប្រទេសផ្សេងៗ បានធ្លាក់ចុះក្នុងរង្វង់ ៣៩,៤%, ៤០,៤%, ២៨,៦% រៀងគ្នាធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២។

ក្រាហ្វិច ៦÷ ទីផ្សារចិន, អាស៊ាន និង អឺរ៉ុបបានរួម ចំណែកធំក្នុងទីផ្សារនាំចូលសរុបរបស់កម្ពុជាក្នុងខែកញ្ញា ឆ្នាំ២០២៣




*ប្រភព÷ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

តារាង ៣÷ ទំហំទឹកប្រាក់នាំចូលតាមមុខទំនិញសំខាន់ៗក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣

| ទំនិញ (គិតជាលានដុល្លារ) | ទំហំទឹកប្រាក់នាំចេញ | សមាមាត្រជាភាគរយ |
|---|---|---|
| ក្រណាត់ | 3,364 | 18.4% |
| គ្រឿងសំណង់ | 1,416 | 7.7% |
| យានយន្ត | 764 | 4.2% |
| ប្រេងឥន្ធនៈ | 1,812 | 9.9% |
| ទំនិញផ្សេងទៀត | 10,861 | 59.4% |
| សរុបដកមាស | 18,217 | 99.7% |

ទំនិញនាំចូលដកមាសមាន ៩៩,៧% នៃទំនិញនាំចូលសរុប

*ប្រភព÷ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

## ១.៣. ស្ថានភាពវិនិយោគ / Investment

នៅក្នុងខែកញ្ញា ឆ្នាំ ២០២៣ ប្រទេសកម្ពុជាទទួលបានគម្រោងវិនិយោគសរុប ២៧ គម្រោង ដែលក្នុងនោះ គម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១៨ គម្រោង (១៧ ជាគម្រោងថ្មី និង ១ ជាគម្រោងពង្រីកចង្វាក់ផលិតកម្ម) និងក្រៅតំបន់សេដ្ឋកិច្ចពិសេសមានគម្រោងថ្មីចំនួន ៩ គម្រោង។ ការវិនិយោគនេះបានប្រើប្រាស់ទុនប្រមាណ ១ ៦២៤ លានដុល្លារ និងមានលទ្ធភាពបង្កើតការងារថ្មីចំនួន ៣២ ០៤៨ នាក់។ បើប្រៀបធៀបទៅនឹងខែសីហា ឆ្នាំ២០២៣ ចំនួនគម្រោងវិនិយោគបានថយចុះ ៤ គម្រោង, ទុនវិនិយោគកើនឡើងក្នុងរង្វង់ ៨៣% និង ការបង្កើតការងារថ្មីបានថយចុះ ៣៨%។

បើធៀបនឹងរយៈពេល ៩ខែ ដើមឆ្នាំ២០២២ ស្ថានភាពវិនិយោគក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ មានភាពល្អប្រសើរដោយ ចំនួនគម្រោងវិនិយោគកើនឡើងចំនួន ៤១ គម្រោង, ការបង្កើតកម្លាំងពលកម្មថ្មីកើនឡើង ២៧% និង ទុនវិនិយោគកើនឡើង ១០៤%។ ជាលទ្ធផល គិតត្រឹមខែកញ្ញា ឆ្នាំ២០២៣ កម្ពុជាទទួលបានគម្រោងវិនិយោគសរុប ១៩១ គម្រោង, បានប្រើប្រាស់ទុនវិនិយោគ ៣,៧ ពាន់លានដុល្លារ និងមានលទ្ធភាពបង្កើតការងារថ្មីចំនួន ២២៦ ៥៥៤ នាក់។

ក្រាហ្វិច ៧÷ ទុនវិនិយោគតាមវិស័យ ៩ខែ ដើមឆ្នាំ ២០២៣




តារាង ៤÷ ស្ថានភាពវិនិយោគសរុប ៩ខែដើមឆ្នាំ២០២០, ២០២១, ២០២២, និង ២០២៣

| | ចំនួនគម្រោងវិនិយោគ | ទំហំទុនវិនិយោគ | ការបង្កើតការងារថ្មី |
|---|---|---|---|
| ៩ ខែ ឆ្នាំ ២០២០ | 188 | 6,443 | 23,509 |
| ៩ ខែ ឆ្នាំ ២០២១ | 134 | 3,359 | 20,841 |
| ៩ ខែ ឆ្នាំ ២០២២ | 150 | 3,460 | 111,004 |
| ៩ ខែ ឆ្នាំ ២០២៣ | 191 | 3,765 | 226,554 |

*ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

## ១.៤. ស្ថានភាពទេសចរណ៍ / Tourism

ក្នុងខែកញ្ញា ឆ្នាំ២០២៣ ចំនួនភ្ញៀវទេសចរអន្តរជាតិបានថមថយបន្តិច ខណៈដែលចំនួនភ្ញៀវទេសចរជាតិមានកំណើនល្អធៀបនឹងខែមុន។ ជាក់ស្តែង ក្នុងខែកញ្ញា ឆ្នាំ២០២៣ កម្ពុជាទទួលបាន ភ្ញៀវទេសចរអន្តរជាតិចំនួន ៤២៤ ៩០១ នាក់ ថយចុះ ៨,៥% និងភ្ញៀវទេសចរជាតិ ចំនួន ៦៤៨ ៩០២ នាក់ កើនឡើង ២០% ធៀបនឹងខែសីហា ឆ្នាំ ២០២៣ ខណៈដែលភ្ញៀវទេសចរអន្តរជាតិទិញសំបុត្រពីគ្រឹះស្ថានអង្គរមានចំនួន ៤១ ០៤៨ នាក់ ថយចុះ ៣០,៦%។

ជាមួយគ្នានេះក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ នេះ កម្ពុជាទទួលបានភ្ញៀវអន្តរជាតិ ចំនួន ៣,៩ លាននាក់ និង ភ្ញៀវទេសចរជាតិ ចំនួន ១១ លាននាក់ ដែលមានកំណើន ប្រមាណ ២៩៧% និង ៣២%រៀងគ្នា ខណៈដែលចំនួនភ្ញៀវទេសចរអន្តរជាតិទិញសំបុត្រពីគ្រឹះស្ថានអង្គរសរុបមានចំនួន ៥៣៩ ៥៦១ នាក់កើនឡើង ៣០២% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២២។

ក្រាហ្វិច ៨÷ ចំនួនភ្ញៀវទេសចរនៅកម្ពុជាគិតត្រឹមខែកញ្ញា ឆ្នាំ២០២៣




*ប្រភព÷ ក្រសួងទេសចរណ៍*

## ១.៥. ស្ថានភាពសំណង់ / Construction

ស្ថានភាពសំណង់ក្នុងខែកញ្ញា ឆ្នាំ២០២៣ បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ដោយសារការធ្លាក់ចុះព្រមគ្នានៃ ចំនួនការអនុញ្ញាតសាងសង់, ទំហំផ្ទៃក្រឡាសាងសង់, និងទំហំទឹកប្រាក់សាងសង់។ ជាក់ស្តែងក្នុងខែកញ្ញានេះ ការអនុញ្ញាតសាងសង់មានចំនួន ២៣១ គម្រោង, មានទំហំផ្ទៃក្រឡាសរុប ៤២៧ ៥៨២ ម៉ែត្រការ៉េ, និងប្រើទំហំទឹកប្រាក់ប្រមាណ ២០២ ២៩៦ ៨៧៩ ដុល្លារ។ បើធៀបនឹងខែសីហា ឆ្នាំ២០២៣ ចំនួននៃការអនុញ្ញាតសាងសង់បានធ្លាក់ចុះ១០០ គម្រោង ស្មើនឹង ៣០%, ផ្ទៃក្រឡាសាងសង់ ធ្លាក់ចុះ ៨៨% និងទំហំទឹកប្រាក់ ធ្លាក់ចុះ ៨៧%។ បើធៀបនឹងខែកញ្ញាឆ្នាំ ២០២២ ចំនួនសំណង់បានធ្លាក់ចុះ ៣៦%, ផ្ទៃក្រឡាសាងសង់ធ្លាក់ចុះ ៤៦% និងទំហំទឹកប្រាក់ធ្លាក់ចុះ ៣២%។

យោងតាមទិន្នន័យគម្រោងទទួលបានការអនុញ្ញាតសាងសង់សរុបមានចំនួន ២៣១ គម្រោង ដែលក្នុងនោះ មានគម្រោងលំនៅដ្ឋានចំនួន ១៩៤ គម្រោង (មានបុរីចំនួន ១៨៨ គម្រោង), សំណង់ឧស្សាហកម្មចំនួន ១៨ គម្រោង, សំណង់ពាណិជ្ជកម្ម ១១ គម្រោង, សំណង់ទេសចរណ៍ចំនួន ៧ គម្រោង និងសំណង់សាធារណៈចំនួន ១ គម្រោង។

គិតត្រឹមខែកញ្ញា ឆ្នាំ២០២៣ គម្រោងសាងសង់សរុបមានចំនួន ២ ៥៩៨ គម្រោង ដែលមានផ្ទៃក្រឡា ១១,៩៩ លានម៉ែត្រការ៉េ និងប្រើប្រាស់ទំហំទឹកប្រាក់អស់ចំនួន ៤ ៩៦០ លានដុល្លារ។ បើធៀបក្នុងរយៈពេល ៩ខែ ដើមឆ្នាំ ២០២២, ចំនួនគម្រោងបានធ្លាក់ចុះចំនួន ៥៧៧ គម្រោង ប៉ុន្តែផ្ទៃក្រឡាសាងសង់ និងទំហំទឹកប្រាក់សាងសង់ កើនឡើង ១៤៦% និង ១៥៣% រៀងគ្នា។




*ប្រភព÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*




*ប្រភព÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices

### ២.១. ថ្លៃប្រេងឥន្ធនៈ

ក្នុងខែកញ្ញា ឆ្នាំ២០២៣ នៅលើទីផ្សារកម្ពុជា, ប្រេងសាំងធម្មតា ថ្លៃជាមធ្យម ៤ ៦៥០ រៀល/ លីត្រ និងប្រេងម៉ាស៊ូត ថ្លៃជាមធ្យម ៤ ៧៨៣ រៀល/ លីត្រ កើនឡើង ១,៥% និង ៣,៦% រៀងគ្នា ធៀបនឹងខែមុន។ ចំណែកនៅលើទីផ្សារអន្តរជាតិ, ប្រេងឆៅ (Brent) ថ្លៃជាមធ្យម ៩៤,០ ដុល្លារ/ បារ៉ែល និងប្រេងឆៅ (WTI) ថ្លៃជាមធ្យម ៨៩,៦ ដុល្លារ/ បារ៉ែល កើនឡើង ៩,១% និង ១០,១% រៀងគ្នាធៀបនឹងខែមុន។

ទោះបីជាមានការឡើងថ្លៃក្នុងរយៈពេល ៣ខែចុងក្រោយនេះ, ប៉ុន្តែថ្លៃប្រេងឥន្ធនៈក្នុងស្រុក និងថ្លៃមធ្យមប្រេងឆៅអន្តរជាតិក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ នៅតែស្ថិតក្នុងសភាពល្អប្រសើរជាងថ្លៃជាមធ្យមឆ្នាំ២០២២។ ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣, ថ្លៃប្រេងឥន្ធនៈក្នុងស្រុកស្ថិតក្នុងរង្វង់ ៤ ២៩៨ រៀល/ លីត្រ ថយចុះ ១៤,៨% ធៀបនឹងរយៈពេល ៩ខែ ដើមឆ្នាំ២០២២ ក្នុងនោះប្រេងសាំង ថយចុះ ១២,៨% និង ប្រេងម៉ាស៊ូត ថយចុះ ១៦,៦%។ ស្របគ្នានេះដែរ, ថ្លៃប្រេងឆៅជាមធ្យមលើទីផ្សារអន្តរជាតិ ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ គឺ ៨០,៣ ដុល្លារ/ បារ៉ែល ថយចុះ ២០,៥% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២២ ដោយប្រេងឆៅ (Brent) ថយចុះ ២០,៧% និងប្រេងឆៅ (WTI) ថយចុះ ២១,២%។ យ៉ាងណាមិញ ថ្លៃប្រេងឥន្ធនៈលក់រាយក្នុងស្រុក និងថ្លៃប្រេងឆៅអន្តរជាតិ នឹងមាននិន្នាការកើនឡើងបន្ត ដែលបណ្តាលមកពីការកាត់បន្ថយការផ្គត់ផ្គង់ប្រេងឆៅពីប្រទេសអារ៉ាប៊ីអូឌីត និងការដាក់ទណ្ឌកម្មលើការនាំចេញប្រេងរបស់ប្រទេសរុស្ស៊ី ពីសំណាក់ប្រទេសលោកខាងលិច គួបផ្សំនឹងឥទ្ធិពលអវិជ្ជមានពីសង្គ្រាមរវាង អ៊ីស្រាអែល និងហាម៉ាស ដែលបានបង្កការភ័យខ្លាចថាអាចនឹងមានការរំខានដល់ការផ្គត់ផ្គង់ប្រេងពីប្រទេសនៅមជ្ឈិមបូព៌ា។

ក្រាហ្វិចទី ១១÷ និន្នាការថ្លៃប្រេងសាំង និងប្រេងម៉ាស៊ូតលើទីផ្សារកម្ពុជា




*ប្រភព÷ ក្រសួងពាណិជ្ជកម្ម*



ក្រាហ្វិចទី ១២÷ និន្នាការថ្លៃប្រេងសាំងស្គង់ដារលើទីផ្សារអន្តរជាតិ

*ប្រភព÷ ធនាគារជាតិ (Pink Sheet)*

**២.២. ថ្លៃអង្ករ÷** ក្នុងខែកញ្ញា ឆ្នាំ២០២៣, នៅលើទីផ្សារកម្ពុជា ថ្លៃអង្ករជាមធ្យម ៣ ៥០២ រៀល/គ.ក្រ កើនឡើង ២,៥% ធៀបនឹងខែមុន ក្នុងនោះ អង្ករផ្កាម្លិះ ថ្លៃជាមធ្យម ៤ ១៣៦ រៀល/គ.ក្រ និង អង្ករផ្កាខ្ញី ថ្លៃជាមធ្យម ៣ ៣៧៨ រៀល/គ.ក្រ កើនឡើង ២,៣% និង ៣,៤% រៀងគ្នា។ គួរកត់សម្គាល់ដែរថា បន្ទាប់ពីបានឡើងថ្លៃក្នុងរយៈពេល ២ខែចុងក្រោយនេះ, ថ្លៃអង្ករជាមធ្យមក្នុងស្រុក នៅសប្តាហ៍ចុងក្រោយនៃខែកញ្ញា ហាក់មានសភាពល្អប្រសើរជាងមុន ដោយថ្លៃអង្ករជាមធ្យមបានថយចុះក្នុងរង្វង់ ១៥០ រៀល/គ.ក្រ ដែលបណ្តាលមកពីការចូលមកដល់នៃរដូវច្រូតកាត់ (ដើមរដូវ)។ ដូចគ្នានេះដែរ, ក្រោយការភ្ញាក់ផ្អើលពីការផ្អាកផ្គត់ផ្គង់អង្កររបស់ប្រទេសឥណ្ឌា បូករួមនឹងការភ័យខ្លាចពីការកង្វះស្បៀងអាហារដោយសារឥទ្ធិពលនៃគ្រោះធម្មជាតិ អែលនីញូ នាពេលកន្លងមក, នៅលើទីផ្សារអន្តរជាតិក្នុងខែកញ្ញា ឆ្នាំ២០២៣ ថ្លៃអង្ករថៃប្រភេទអង្ករបាក់ ៥% បានថយចុះមកវិញបន្តិច ខណៈដែលថ្លៃអង្កររៀតណាមនៅបន្តកើនឡើងនៅឡើយ, ជាក់ស្តែង អង្ករថៃប្រភេទអង្ករបាក់ ៥% ថ្លៃជាមធ្យម ៦២០,០ ដុល្លារ/តោន ថយចុះ ២,៤ ធៀបនឹងខែមុន តែអង្កររៀតណាមប្រភេទអង្ករបាក់ ៥% ថ្លៃជាមធ្យម ៥៩៤,៤ ដុល្លារ/តោន កើនឡើង ៩,៨%។

ជាមួយគ្នានេះ ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣, នៅលើទីផ្សារកម្ពុជាថ្លៃអង្ករលក់រាយគិតជាមធ្យមស្ថិតក្នុងរង្វង់ ៣ ១៧២ រៀល/គ.ក្រ កើនឡើង ៦,៨% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២២ ដែលរួមចំណែកដោយ អង្ករផ្កាម្លិះ ថ្លៃជាមធ្យម ៣ ៧៨៩ កើនឡើង ៥,៧% និងអង្ករផ្កាខ្ញី ថ្លៃជាមធ្យម ២ ៩២២ កើនឡើង ១៣,៣%។ ទន្ទឹមនេះ ថ្លៃអង្ករជាមធ្យមលើទីផ្សារអន្តរជាតិក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៣ នេះ រួមមាន អង្ករថៃប្រភេទបាក់ ៥% ថ្លៃជាមធ្យម

៥៣៤,៧ ដុល្លារ/តោន កើនឡើង ២៣,៣% និងអង្ករវៀតណាមប្រភេទបាក់ ៥% ថ្លៃជាមធ្យម ៤៨៩,៥ ដុល្លារ/តោន កើនឡើង ២២,៧% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២២។



ក្រាហ្វិចទី ១៣÷ និន្នាការថ្លៃអង្ករស្តង់ដារលើទីផ្សារកម្ពុជា

*ប្រភព÷ ការចុះស្រង់ថ្លៃទំនិញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋានគោលនយោបាយពីផ្សារចំនួន ៤ នៃរាជធានីភ្នំពេញ*



ក្រាហ្វិចទី ១៤÷ និន្នាការថ្លៃអង្ករស្តង់ដារលើទីផ្សារអន្តរជាតិ

*ប្រភព÷ ធនាគារពិភពលោក (Pink Sheet)*

# ៣. ឧបសម្ព័ន្ធ

## ៣.១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia Economic Trends

### ៣.១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

តារាង ៣.១.១÷ ការប្រែប្រួលសន្ទស្សន៍ថ្លៃនៃក្រុមទំនិញទាំង ១២ ខែកញ្ញា ឆ្នាំ២០២៣ គិតជា%

| បរិយាយ | ២០២២ | | ២០២៣ | | ២០២២ | | ២០២៣ | |
|---|---|---|---|---|---|---|---|---|
| | ធៀបនឹងខែមុន (MoM) | | | | ធៀបនឹងឆ្នាំមុន (YoY) | | | |
| | សីហា | កញ្ញា | សីហា | កញ្ញា | សីហា | កញ្ញា | សីហា | កញ្ញា |
| **មុខទំនិញគ្រប់មុខ** | **-0.5%** | **-0.5%** | **0.9%** | **0.0%** | **4.9%** | **4.4%** | **3.2%** | **3.8%** |
| ១. អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | -0.4% | 0.1% | 0.6% | 0.2% | 4.3% | 4.5% | 4.2% | 4.3% |
| ២. ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | -0.2% | 0.0% | 0.7% | 0.7% | 1.1% | 1.2% | 3.3% | 4.0% |
| ៣. សំលៀកបំពាក់ និងស្បែកជើង | -0.1% | 0.5% | 0.7% | 0.1% | 6.1% | 6.4% | 4.2% | 3.8% |
| ៤. ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | -0.8% | -0.6% | 0.5% | 0.0% | 4.9% | 4.5% | 1.9% | 2.4% |
| ៥. គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | -0.1% | 0.0% | 0.2% | 0.0% | 3.4% | 3.6% | 1.7% | 1.7% |
| ៦. សុខាភិបាល | -0.5% | -0.3% | 0.2% | -0.3% | 1.6% | 1.4% | 1.6% | 1.5% |
| ៧. ការដឹកជញ្ជូន | -0.1% | -2.9% | 3.4% | -0.4% | 8.8% | 5.3% | 0.2% | 2.7% |
| ៨. គមនាគមន៍ | -0.1% | -0.1% | 0.1% | -0.1% | 0.1% | -0.2% | 0.4% | 0.4% |
| ៩. ការកំសាន្ត និងវប្បធម៌ | 0.0% | -0.5% | 0.6% | -0.5% | 6.7% | 5.9% | 3.9% | 3.9% |
| ១០. ការសិក្សា | 0.0% | 0.0% | 0.0% | 0.0% | 2.5% | 2.5% | 2.0% | 2.0% |
| ១១. ភោជនីយដ្ឋាន | -1.0% | -2.3% | 1.4% | -0.5% | 8.2% | 5.0% | 2.9% | 4.8% |
| ១២. ទំនិញ និងសេវាកម្មផ្សេងៗ | -0.4% | -0.4% | 0.3% | -0.2% | 2.7% | 2.6% | 3.0% | 3.3% |

*ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ (NIS)*

*សម្គាល់÷ ក្នុងតារាង ),) ស្មើកាត់ខ្ទង់ និង ).) ស្មើក្បៀស*

### ៣.១.២. វិស័យពាណិជ្ជកម្ម / Trade

តារាង ៣.១.២÷ ការនាំចូលនិងការនាំចេញតាមមុខទំនិញសំខាន់ៗខែកញ្ញា ឆ្នាំ២០២៣ (លានដុល្លារ)

| សូចនាករ | ២០២១ | ២០២២ | ២០២៣ | ២០២៣ | | | Δ% | | |
|---|---|---|---|---|---|---|---|---|---|
| | ៩ខែ | ៩ខែ | ៩ខែ | កក្កដា | សីហា | កញ្ញា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៩ខែ) |
| **តម្លៃនាំចេញសរុប (I)** | **14,139** | **17,258** | **17,597** | **2,061** | **2,167** | **1,905** | **-12.1%** | **17.8%** | **2.0%** |
| **តម្លៃនាំចេញសរុប (ដកមាសចេញ)** | **14,050** | **17,077** | **16,946** | **2,023** | **2,118** | **1,881** | **-11.2%** | **17.2%** | **-0.8%** |
| វាយនភណ្ឌ និងស្បែកជើង | 8,088 | 10,111 | 8,332 | 1,105 | 1,007 | 9,54 | **-5.3%** | **-3.3%** | **-17.6%** |
| កង់ | 472 | 700 | 360 | 25 | 34 | 22 | **-35.0%** | **-69.4%** | **-48.6%** |
| អង្ករ | 286 | 291 | 328 | 25 | 25 | 50 | **99.4%** | **17.7%** | **12.6%** |
| ដំឡូងមី | 404 | 534 | 539 | 29 | 55 | 50 | **-9.0%** | **126.9%** | **0.8%** |
| ជ័រកៅស៊ូ | 266 | 273 | 287 | 32 | 37 | 54 | **46.2%** | **96.0%** | **5.1%** |
| ទំនិញផ្សេងៗ | 4,624 | 5,349 | 7,751 | 8,45 | 1,009 | 775 | **-23.2%** | **66.1%** | **44.9%** |
| **តម្លៃនាំចូលសរុប (II)** | **20,622** | **23,764** | **18,272** | **1,946** | **2,105** | **1,992** | **-5.4%** | **-0.4%** | **-23.1%** |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **តម្លៃនាំចូលសរុប (ដកមាសចេញ)** | **16,532** | **19,363** | **18,217** | **1,940** | **2,092** | **1,955** | **-6.6%** | **4.1%** | **-5.9%** |
| ក្រណាត់ | 3,507 | 3,873 | 3,364 | 335 | 384 | 409 | **6.7%** | **29.5%** | **-13.2%** |
| គ្រឿងសំណង់ | 1,243 | 1,405 | 1,416 | 153 | 179 | 163 | **-8.9%** | **43.2%** | **0.8%** |
| យានយន្ត | 872 | 1,166 | 764 | 76 | 81 | 80 | **-1.1%** | **-50.2%** | **-34.4%** |
| ប្រេងឥន្ធនៈ | 1,268 | 2,079 | 1,812 | 211 | 207 | 214 | **3.6%** | **-15.1%** | **-12.8%** |
| ទំនិញផ្សេងៗទៀត | 13,731 | 15,241 | 10,916 | 1,172 | 1,254 | 1,125 | **-10.3%** | **-2.8%** | **-28.4%** |
| **តុល្យភាពពាណិជ្ជកម្ម (I-II)** | **-6,482** | **-6,506** | **-675** | **115** | **62** | **-87** | | | |

*ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*

*សម្គាល់៖ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ៣.១.៣. ស្ថានភាពវិនិយោគ / Investment

**តារាង ៣.១.៣៖ ស្ថានភាពវិនិយោគខែកញ្ញា ឆ្នាំ២០២៣**

| សូចនាករ | ឯកតា | ២០២២ | ២០២២ | ២០២៣ | ២០២៣ | | | Δ% | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | ៩ខែ | ៩ខែ | កក្កដា | សីហា | កញ្ញា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៩ខែ) |
| ចំនួនគម្រោង | គម្រោង | 186 | 150 | 191 | 15 | 36 | 27 | -9 | 4 | 41 |
| ចំនួនទុនវិនិយោគ | លាន($) | 4,033 | 3,459.6 | 3,765.4 | 148.1 | 887.7 | 1,624.0 | 82.94% | 784.61% | 8.84% |
| ចំនួនការងារបង្កើត | ពាន់នាក់ | 143,811 | 111,004 | 226,554 | 20,892 | 51,433 | 32,048 | -37.69% | 67.34% | 104.10% |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

*សម្គាល់៖ ១)* គិតជាចំនួនគម្រោង ២) ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ៣.១.៤. ស្ថានភាពទេសចរណ៍ / Tourism

**តារាង ៣.១.៤៖ ចំនួនភ្ញៀវអន្តរជាតិ ខែកញ្ញា ឆ្នាំ២០២៣ (ពាន់នាក់)**

| សូចនាករសំខាន់ៗ | ២០២២ | ២០២២ | ២០២៣ | ២០២៣ | | | Δ% | | |
|---|---|---|---|---|---|---|---|---|---|
| | | ៩ខែ | ៩ខែ | កក្កដា | សីហា | កញ្ញា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៩ខែ) |
| **សរុប** | **2,277** | **1266** | **3927** | **457** | **465** | **425** | **-9%** | **59%** | **210%** |
| **តាមអាកាស** | **792** | **469** | **1341** | **152** | **149** | **127** | **-15%** | **76%** | **186%** |
| ច្រកអន្តរជាតិភ្នំពេញ | 610 | 386 | 999 | 117 | 109 | 98 | -10% | 74% | **159%** |
| ច្រកសៀមរាប | 165 | 70 | 330 | 34 | 38 | 27 | -28% | 93% | **371%** |
| ច្រកកងកេង | 17 | 13 | 12 | 1 | 1 | 1 | -3% | -30% | **-7%** |
| **តាមផ្លូវគោកនិងទឹក** | **1,485** | **797** | **2586** | **305** | **316** | **298** | **-6%** | **53%** | **225%** |
| ផ្លូវគោក | 1,467 | 789 | 2545 | 302 | 312 | 295 | -6% | 52% | **223%** |
| ផ្លូវទឹក | 18 | 8 | 41 | 3 | 4 | 3 | -17% | 138% | **394%** |
| ទេសចរបរទេសចូលទស្សនារមណីយដ្ឋានអង្គរ | 287 | 123 | 139 | 54 | 59 | 41 | -31% | 74% | **302%** |

ប្រភព៖ ក្រសួងទេសចរណ៍
សម្គាល់៖ ក្នុងតារាង (,) ស្មើកាត់ខ្នង់ និង (.) ស្មើក្បៀស

## ៣.១.៥. ស្ថានភាពសំណង់ / Construction

| តារាង ៣.១.៥៖ ស្ថានភាពសំណង់ ខែកញ្ញា ឆ្នាំ២០២៣ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០២២ | ២០២២ ៩ខែ | ២០២៣ ៩ខែ | ២០២៣ | | | Δ % | | |
| | | | | | កក្កដា | សីហា | កញ្ញា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៩ខែ) |
| សរុបចំនួនគម្រោង* | ចំនួន | 4,275 | 3,175 | 2,598 | 187 | 331 | 231 | -100 | -133 | -577 |
| សរុបជាផ្ទៃក្រឡា | ពាន់ម² | 7,278 | 4,867 | 11,991 | 1,183 | 3,563 | 428 | -88% | -46% | 146% |
| សរុបជាទឹកប្រាក់ | លាន($) | 2,968 | 1,959 | 4,960 | 440 | 1,558 | 202 | -87% | -32% | 153% |

ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
សម្គាល់៖ ១)*គិតជាចំនួនគម្រោង ២)ក្នុងតារាង (,) ស្មើកាត់ខ្នង់ និង (.) ស្មើក្បៀស

## ៣.២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity Prices

| តារាង ៣.២៖ ស្ថានភាពថ្លៃទំនិញសំខាន់ៗ (ថ្លៃមធ្យមប្រចាំខែ) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | | ឯកតា | ២០២២ | | | ២០២៣ | | | Δ % | |
| | | | កក្កដា | សីហា | កញ្ញា | កក្កដា | សីហា | កញ្ញា | ខែមុន | ឆ្នាំមុន |
| ក្នុងស្រុក | សាំងធម្មតា | រៀល/ លីត្រ | 5,283 | 4,683 | 4,483 | 4,150 | 4,583 | 4,650 | 1.5% | 3.7% |
| | ម៉ាស៊ូត | រៀល/ លីត្រ | 5,700 | 5,083 | 5,183 | 3,983 | 4,617 | 4,783 | 3.6% | -7.7% |
| | ហ្គាស | រៀល/១៥គ.ក្រ | 81,750 | 79,000 | 77,000 | 76,600 | 77,500 | 77,500 | 0.0% | 0.6% |
| | អង្ករផ្កាម្លិះ | រៀល/គ.ក្រ | 3,579 | 3,605 | 3,633 | 3,817 | 4,089 | 4,136 | 1.2% | 13.8% |
| | អង្ករផ្កាខ្ញី | រៀល/គ.ក្រ | 2,585 | 2,620 | 2,664 | 3,025 | 3,312 | 3,378 | 2.0% | 26.8% |
| | អង្ករនាងមិញ | រៀល/គ.ក្រ | 2,780 | 2,785 | 2,809 | 2,750 | 2,984 | 2,993 | 0.3% | 6.5% |
| អន្តរជាតិ | Average Oil Price | ដុល្លារ/ បារ៉ែល | 105.1 | 96.0 | 88.2 | 78.9 | 84.7 | 92.2 | 8.8% | 4.5% |
| | Brent | ដុល្លារ/ បារ៉ែល | 108.9 | 98.6 | 90.2 | 80.1 | 86.2 | 94.0 | 9.1% | 4.3% |
| | Dubai | ដុល្លារ/ បារ៉ែល | 106.5 | 97.8 | 90.6 | 80.5 | 86.6 | 93.1 | 7.5% | 2.7% |
| | WTI | ដុល្លារ/ បារ៉ែល | 99.9 | 91.6 | 83.9 | 76.4 | 81.4 | 89.6 | 10.0% | 6.8% |
| | អង្ករថៃ (៥%) | ដុល្លារ/ តោន | 418.0 | 431.0 | 439.0 | 547.0 | 635.0 | 620.0 | -2.4% | 41.2% |
| | អង្កររៀតណាម (៥%) | ដុល្លារ/ តោន | 411.1 | 395.8 | 392.2 | 502.8 | 541.2 | 594.4 | 9.8% | 51.5% |
| | អង្ករថៃ (២៥%) | ដុល្លារ/ តោន | 412.0 | 421.0 | 428.0 | 524.0 | 600.0 | 587.0 | -2.2% | 37.1% |
| | អង្ករថៃ A.1 (100%) | ដុល្លារ/ តោន | 405.7 | 412.6 | 423.4 | 533.5 | 626.0 | 609.9 | -2.6% | 44.1% |

ប្រភព& ចំណាំ៖ វិទ្យាស្ថានជាតិស្ថិតិ (NIS), ក្រសួងពាណិជ្ជកម្ម, World Bank, អ.ប.ត.